# អ្នកស្រី ប្រាយ នីម



*“ត្រូវរៀនឱ្យមានជំនាញសម្រាប់ខ្លួនឯង មិនត្រូវខ្លាចចំពោះអ្នកដែលមិនឱ្យតម្លៃយើង និងហ៊ានធ្វើអ្វីៗដែលខ្លួនចង់ធ្វើ ដើម្បីខ្លួនឯងរួមទាំងសង្គមផងដែរ។ ត្រូវមានសង្ឃឹមជានិច្ច ព្យាយាមចូលរួមការងារសង្គម និងស្តាប់ព័ត៌មានឱ្យបានច្រើន ដើម្បីជាមូលដ្ឋានក្នុងការធ្វើការសម្រេចចិត្តទៅថ្ងៃអនាគត។”*

អ្នកស្រី ប្រាយ នីម មានអាយុ ៤១ ឆ្នាំជាអ្នកលក់បន្លែ និងរកស៊ីបោកអ៊ុតនៅផ្ទះ បន្ថែមពីលើមុខរបរប្រចាំថ្ងៃ អ្នកស្រីបានក្លាយជាសកម្មជនការពារសិទ្ធិដីធ្លី និងសិទ្ធិស្ត្រីយ៉ាងសកម្មតាំងពីឆ្នាំ២០១២ មកម្ល៉េះ។ មុនដំបូង អ្នកស្រីគឺជាស្ត្រីមេផ្ទះម្នាក់ដែលប្តីជាមន្ត្រីរាជការ ហើយសេដ្ឋកិច្ចគឺពឹងផ្អែកលើប្តីទាំងស្រុង។ នៅឆ្នាំ២០១២ សហគមន៍ និងអ្នកស្រីផ្ទាល់បានទទួលរងការរំលោភបំពានសិទ្ធិដីធ្លី ហើយពេលនោះ អ្នកភូមិមិនសូវហ៊ានចេញមុខតវ៉ា និងមានភាពអត្មានិយម ដូច្នេះ អ្នកស្រីបានចេញមុខធ្វើការតស៊ូមតិដើម្បីការពារសិទ្ធិរបស់ខ្លួន និងសហគមន៍ផងដែរ។ នៅពេលនោះ អ្នកស្រីត្រូវបានសហគមន៍សម្រេចបោះឆ្នោតជ្រើសរើសធ្វើជាតំណាងរបស់ពួកគេ ដើម្បីសម្របសម្រួល និងដឹកនាំសកម្មភាពតស៊ូមតិផ្សេងៗ។

អ្នកស្រីបានចូលរួមសកម្មភាពជាច្រើនដើម្បីធ្វើការទាមទារ និងការពារសិទ្ធិដីធ្លីរបស់ខ្លួន និងសហគមន៍ទាំងមូល។ សកម្មភាពទាំងនោះដូចជា ការតវ៉ាដោយសន្តិវិធី ការប្រជុំពង្រឹងអំណាចសហគមន៍ ការតស៊ូមតិតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងការប្រឹក្សាផ្លូវចិត្តដល់ស្ត្រីដែលជួបបញ្ហាស្រដៀងៗនឹងខ្លួនផងដែរ។

អ្នកស្រីបានឆ្លងកាត់បញ្ហាប្រឈមជាច្រើន ដែលពេលខ្លះបានធ្វើឱ្យគាត់ស្ទើតែវង្វេង និងចង់សម្លាប់ខ្លួនម្តងៗ។ បញ្ហាទាំងនោះដូចជា ការរើសអើងពីសំណាក់សាច់ញ្ញាតិខាងប្តី ការប្រើប្រាស់អំពើហិង្សាទាំងរាងកាយ ផ្លូវសេដ្ឋកិច្ច និងផ្លូវចិត្តពីប្តី ដើម្បីបង្ខំឱ្យអ្នកស្រីបញ្ឈប់សកម្មភាពតវ៉ា និងសកម្មភាពតស៊ូមតិផ្សេងៗ។ អ្នកស្រីត្រូវបានប្តីលែងលះ និងសាច់ញ្ញាតិខាងប្តីឈប់រាប់រក ហើយជីវភាពធ្លាក់ដល់កំរឹតសូន្យ កូនឈឺមិនមានលទ្ធភាពមើលថៃ ធ្លាប់ជាប់ឃុំ មានជំងឺផ្លូវចិត្តទៀតផង ដោយសារតែខ្លួនមិនព្រមបញ្ឈប់សកម្មភាពតស៊ូមតិ។ ទោះយ៉ាងណា បញ្ហាប្រឈមទាំងនោះមិនបានរារាំងអ្នកស្រីក្នុងសកម្មភាពតស៊ូមតិ និងកិច្ចការងារសង្គមនោះឡើយ ប៉ុន្តែបានក្លាយជាកត្តាជម្រុញឱ្យអ្នកស្រីមានភាពរឹងមាំកាន់តែខ្លាំង។ ជាលទ្ធផល សហគមន៍ និងអ្នកស្រីទទួលបានភាពជោគជ័យជាច្រើនដូចជា ទទួលបានការជូនដំណឹងនៃការបញ្ឈប់ការបណ្តេញ សហគមន៍មានភាពរឹងមាំ ហើយអ្នកស្រីបានក្លាយជាសកម្មជនដីធ្លី និងស្ត្រីយ៉ាងសកម្មដែលមិនត្រឹមតែជួយសហគមន៍ខ្លួន ប៉ុន្តែអ្នក

ស្រីបានជួយដល់សហគមន៍ផ្សេងៗ តាមរយៈការផ្សព្វផ្សាយ ពង្រឹងអំណាច និងការចូលរួមសកម្មភាពតវ៉ាផ្សេងៗផងដែរ។

ក្នុងនាមជាសកម្មជនសិទ្ធិដីធ្លី និងសិទ្ធិស្ត្រី ហើយក៏ធ្លាប់ជាជនរងគ្រោះដោយខ្លួនជាស្ត្រីមេផ្ទះ អ្នកស្រីយល់ថា សមភាពយេនឌ័រ គឺសំដៅលើការឱ្យតម្លៃ មានសិទ្ធិស្មើគ្នា បុរសធ្វើអ្វីបាន ស្ត្រីក៏ធ្វើបានដូចគ្នា ហើយទាំងនោះមិនត្រូវមានតែក្នុងក្រដាស ឬតែការនិយាយនោះទេ។ ប្រសិនបើមិនមានសមភាពយេនឌ័រ នឹងធ្វើឱ្យប៉ះពាល់អារម្មណ៍ មានបញ្ហាជំងឺផ្លូវចិត្តជាដើម។ល។ ឧទាហរណ៍៖ អ្នកស្រីត្រូវបានប្តីលែងដោយសារតែខ្លួនជំនះចូលរួមការតស៊ូមតិ និងជួបបញ្ហាជាច្រើនដោយសារតែខ្លួនជាស្ត្រី។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights
BY NC SA
ខែធ្នូ ឆ្នាំ២០១៩